ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២២៤........ប្រក.កសក

នាយកដ្ឋាន
ផលិតកម្ម & បសុព្យាបាល
ចូល
លេខ ...1591......
ថ្ងៃទី...30/06/08
ម៉ោង.....9.00h.....

# ប្រកាស

## ស្តីពី

## បទបញ្ជាផ្ទៃក្នុង របស់សត្តឃាតដ្ឋាន

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក. ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក. ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ ១ :** ដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុង របស់សត្តឃាតដ្ឋាន ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល គ្រប់ប្រធានអង្គភាពដែលមានការពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និង ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារៈកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

លេខ : ១០០៥ ផប

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និង បញ្ជូនមក :

លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលគ្រប់ខេត្ត ក្រុង

" ដើម្បីអនុវត្ត "

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៨

**ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

**កៅ ផល**

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសលេខ ៦៦៤ ប្រក.កសក
ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨

# បទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន

ដើម្បីធានាបាននូវអនាម័យសត្វ សាច់ និង ផលិតផលសត្វ សំដៅរក្សាបានសុវត្ថិភាពចំណីអាហារ និង សុខភាពសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រេចកំណត់នូវបទបញ្ជាផ្ទៃក្នុង សម្រាប់សត្តឃាតដ្ឋានទាំងអស់ដូចខាងក្រោម ÷

## ១. អនាម័យសត្តឃាតដ្ឋាន អនាម័យសម្ភារៈពិឃាតសត្វ និង សណ្តាប់ធ្នាប់ក្នុងសត្តឃាតដ្ឋាន

- សត្តឃាតដ្ឋានត្រូវមានអនាម័យ និង ធ្វើការលាងសម្អាត សម្លាប់មេរោគតាមលក្ខណៈបច្ចេកទេសបសុពេទ្យ
- សម្ភារៈប្រើប្រាស់សម្រាប់ការពិឃាតសត្វ ត្រូវមានអនាម័យល្អ
- អ្នកគ្មានភារៈកិច្ច ហាមចេញ ចូល សត្តឃាតដ្ឋានដោយគ្មានការអនុញ្ញាត
- ត្រូវរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និង របៀបរៀបរយក្នុងសត្តឃាតដ្ឋាន។

## ២. អនាម័យ និង សុខុមាលភាពសត្វ មុនពិឃាត

- សត្វសម្រាប់ពិឃាត ត្រូវរក្សាទុកនៅកន្លែងបង្ខាំងសត្វក្នុងសត្តឃាតដ្ឋាន រយៈពេលពី ១២-២៤ ម៉ោង (ដប់ពីរទៅម្ភៃបួន) មុនធ្វើការពិឃាត ដើម្បីឱ្យភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រួតពិនិត្យសុខភាព
- សត្វត្រូវផ្តល់ទឹកផឹកឱ្យបានគ្រប់គ្រាន់ តែមិនផ្តល់អាហារឡើយ ក្នុងរយៈពេលបង្ខាំងនេះ
- ហាមធ្វើទារុណកម្មសត្វដូចជា៖ វាយដំ បញ្ចុកទឹក បញ្ចុកចំណី និង ការធ្វើទារុណកម្មតាមរូបភាពផ្សេងៗទៀត
- សត្វអាចពិឃាតបាន លុះត្រាតែមានការអនុញ្ញាតពីភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច នៅក្នុងសត្តឃាតដ្ឋាននោះ
- សត្វត្រូវលាងសម្អាតឱ្យបានស្អាត មុនធ្វើការពិឃាត។

## ៣. អនាម័យផ្ទាំងសាច់ និង ផលិតផលសត្វ

- ផ្ទាំងសាច់ និង ផលិតផលសត្វ ត្រូវលាងសម្អាត រក្សាទុក ឬ ព្យួរតាមលក្ខណៈបច្ចេកទេស
- សាច់ និង ផលិតផលសត្វ ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យអនាម័យ បោះត្រា ឬ អូសត្រា ឬ បិទស្លាកសម្គាល់លើកញ្ចប់សាច់ និង មានវិញ្ញាបនបត្របញ្ជាក់អនាម័យ ពីភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច មុនធ្វើការនាំចេញពីសត្តឃាតដ្ឋាន
- អាជីវករពិឃាតសត្វ ត្រូវតែបង្កលក្ខណៈងាយស្រួល ដល់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យសត្វ សាច់ ផលិតផលសត្វ និង ការយកវត្ថុវិភាគ។

## ៤. អនាម័យបុគ្គលិក កម្មករ និង អ្នកបំពេញការងារក្នុងសត្តឃាតដ្ឋាន

- បុគ្គលិក កម្មករ និង អ្នកបំពេញការងារក្នុងសត្តឃាតដ្ឋាន ត្រូវមានសុខភាពល្អ ( មានលិខិតបញ្ជាក់សុខភាពពី មន្ទីរសុខាភិបាល / អង្គភាពមានសមត្ថកិច្ច )
- ត្រូវមានអនាម័យល្អ ហាមខាកស្តោះ និង ជក់បារី ក្នុងពេលម៉ោងកំពុងធ្វើការ ។

## ៥. សម្លៀកបំពាក់ សម្រាប់អ្នកបំពេញការងារនៅក្នុងសត្តឃាតដ្ឋាន

- អាវដៃខ្លី ឬ ដៃវែងជីបចុងដៃ ក្រណាត់ពណ៌ផ្ទៃមេឃ
- ខោជើងវែង ក្រណាត់ពណ៌ផ្ទៃមេឃ
- គម្របក្បាល ក្រណាត់ពណ៌ផ្ទៃមេឃ
- ស្បែកជើងកវែង មិនជ្រាបទឹក ពណ៌ស
- អាវអៀមផ្លាស្ទិក ពណ៌ស
- ស្រោមដៃ ពណ៌ស ។